# លក្ខន្តិកៈ សហជីព មន្ទីរពេទ្យកាល់ម៉ែត

# STATUT DU SYNDICAT DE L'HOPITAL CALMETTE

## ជំពូក I

## ឈ្មោះសហជីព . គោលបំណង . ទីស្នាក់ការ

<u>ប្រការ ១</u>

យោងតាមបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យកាល់ម៉ែត មន្ត្រី រាជការ បុគ្គលិក កម្មករ មន្ទីរពេទ្យ បានពិភាក្សានិងឯកភាពបង្កើត សហជីពមួយឈ្មោះហៅថា <u>សហជីពមន្ទីរពេទ្យកាល់ម៉ែត</u> អក្សរកាត់ "ស.ម.ក" ជាភាសាបារាំង SYNDICAT DE L'HOPITAL CALMETTE ( S.H.C ) ។

<u>ប្រការ ២</u>

សហជីពមានគោលបំណង

- ប្រមូលផ្តុំ បុគ្គលិក កម្មករទាំងអស់ នៃមន្ទីរពេទ្យកាល់ម៉ែត ក្នុងគោលបំណងរឹតចំណង សាមគ្គីភាព ភាតរៈភាពនិងការយោគយល់គ្នា ។
- ផ្តល់ការជួយឧបត្ថម្ភគ្នាទៅវិញទៅមក ទាំងស្មារតី និង សំភារៈ ។
- ទំនាក់ទំនងជាមួយ អង្គការ - សមាគម - សហជីពនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ល្អទៅវិញទៅមក ។
- សហជីពមិនធ្វើនយោបាយ ហើយគោរពតាមច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ។

<u>ប្រការ ៣</u>

ទីស្នាក់ការអចិន្ត្រៃយ៍របស់សហជីព មានទីតាំងក្នុងបរិវេណមន្ទីរពេទ្យកាល់ម៉ែត តាមការឯកភាពពីនាយករបស់មន្ទីរពេទ្យ ។

## ជំពូក II

## សមាជិក . ការសុំចូលជាសមាជិក

<u>ប្រការ ៤</u>

សហជីពមាន

-សមាជិក កិត្តិយស

-សមាជិក សកម្ម

**ប្រការ ៥**

អាចជាសមាជិកកិត្តិយសបាន គ្រប់ជនទាំងឡាយណាដែលមានតួនាទីជា នាយក ឬ នាយករងមន្ទីរពេទ្យ ។ អាចជាសមាជិកសកម្ម គ្រប់បុគ្គលិក កម្មករ មន្ទីរពេទ្យ ទាំងឡាយណាដែលព្រមបង់ប្រាក់ដោយស្ម័គ្រចិត្ត ជាសិទ្ធិសុំចូលចំនួន ១.០០០ រៀល និងបង់វិភាគទានប្រចាំខែ ៥០០ រៀល ។

**ប្រការ ៦**

អាចចូលជាសមាជិកសហជីពបានគ្រប់ជនដែលជា :

-មន្ត្រី រាជការ មន្ទីរពេទ្យ

-បុគ្គលិក កម្មករ មន្ទីរពេទ្យ

-បុគ្គលិក កម្មករ អណ្តែត មន្ទីរពេទ្យ

ដែលបានធ្វើពាក្យសុំចូលជាសមាជិក ជូនទៅគណៈកម្មាធិការសហជីព ។

**ប្រការ ៧**

ការបាត់បង់សមាជិកភាពអាចកើតមានដោយ :

-ការសុំលាលែង

-ការមិនបានបង់វិភាគទានរយៈបីខែជាប់គ្នា

-មរណៈភាព

-ការអះអាងបន្ថែមពីគណៈកម្មាធិការសហជីពទៅលើការប្រព្រឹត្តខុសបណ្តាលអោយមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស ឬ ផលប្រយោជន៍សហជីព ។

## ជំពូក II

## ការងារអភិបាល និង ដំណើរការ

**ប្រការ ៨**

សហជីពមន្ទីរពេទ្យកាល់ម៉ែត ត្រូវដឹកនាំដោយគណៈកម្មាធិការ ដែលមានសមាសភាព យ៉ាងតិចប្រាំរូប ដែលជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយមហាសន្និបាត សំរាប់អាណត្តិរយៈពេល ៣ ឆ្នាំ ។ សមាជិកដែលអាចឈរឈ្មោះបោះឆ្នោតបាន គឺសមាជិកសកម្ម ។ សមាជិកទាំងនោះអាចឈរឈ្មោះជ្រើសតាំងជាថ្មីនៅក្នុងអណត្តិក្រោយ ។

- គណៈកម្មាធិការមានសមាសភាពប្រាំរូប គឺ

- ប្រធានមួយរូប ដែលមានមុខងារបន្ថែមជាសមាជិកពេញសិទ្ធិនៃក្រុមប្រឹក្សាភិបាល ក្នុងនាមជាតំណាងមន្ត្រីរាជការ បុគ្គលិក កម្មករ មន្ទីរពេទ្យ
- អនុប្រធានមួយរូប
- អគ្គលេខាមួយរូប
- អគ្គលេខារងមួយរូប
- អគ្គហេរញ្ញិកមួយរូប

+ ការជ្រើសតាំងធ្វើឡើង ដោយការបោះឆ្នោតសំងាត់ពីសមាជិកអង្គសន្និបាត ។ បែបបទបោះឆ្នោតនឹងកំណត់នៅពេលធ្វើមហាសន្និបាត ។

+ ក្នុងករណីបាត់បង់សមាជិកគណៈកម្មាធិការណាមួយ គណៈកម្មាធិការត្រូវជ្រើសរើសសមាជិកជំនួសបណ្តោះអាសន្នរហូតដល់មហាសន្និបាតលើកក្រោយ ។

## ប្រការ ៩

គណៈកម្មាធិការ ត្រូវប្រជុំមួយដងក្នុងមួយត្រីមាស តាមការអញ្ជើញរបស់ប្រធាន ។ បើមានការចាំបាច់ ការប្រជុំវិសាមញ្ញត្រូវមានការស្នើយ៉ាងតិចមួយភាគបួននៃសមាជិកទាំងអស់ ។ សេចក្តីសំរេចផ្សេងៗ ត្រូវកំណត់ដោយសំឡេងភាគច្រើនរបស់សមាជិក គណៈកម្មាធិការ ។ ក្នុងករណីសំឡេងស្មើគ្នា មតិរបស់ប្រធានយកជាបានការ ។

រាល់សមាជិករបស់ គណៈកម្មាធិការ ដែលឈប់អត់ដំណឹងមិនបានប្រជុំបីដងជាប់ៗគ្នា ត្រូវចាត់ទុកជាអ្នកបោះបង់ពីតំណែង ។

## ប្រការ ១០

សមាជិកត្រូវធ្វើមហាសន្និបាតរាល់បីឆ្នាំម្តង ។ សមាជិកត្រូវកោះអញ្ជើញដោយអគ្គលេខាយ៉ាងតិចមួយអាទិត្យមុនកាលបរិច្ឆេទប្រជុំ ហើយរបៀបវារៈត្រូវបានចុះក្នុងលិខិតកោះអញ្ជើញនោះ ។ ប្រធានគណៈកម្មាធិការ ត្រូវធ្វើជាអធិបតីរបស់មហាសន្និបាត និង រាយការណ៍ ពីសកម្មភាពរបស់សហជីព ។

-អគ្គហិរញ្ញិករាយការណ៍ពីការគ្រប់គ្រង ចំណូលចំណាយកន្លងមក ជូនមហាសន្និបាតអនុម័ត ។

-ការបោះឆ្នោតសំងាត់ជ្រើសរើសសមាជិកថ្មីនៃគណៈកម្មាធិការ ជំនួសសមាជិកចេញ ត្រូវធ្វើបន្ទាប់ពីរបៀបវារៈ ។

-ក្នុងមហាសន្និបាតត្រូវលើកយកមកនិយាយតែកិច្ចការណា ដែលមានចុះក្នុងរបៀបវារៈ ។

-អង្គមហាសន្និបាតអាចដំណើរការបាន ត្រូវមានវត្តមាន ២/៣ នៃសមាជិកសកម្មជាការចាំបាច់ ។

-សំឡេងដែលអាចយកជាការបាន ត្រូវយកភាគច្រើននៃសំឡេងអ្នកវត្តមាន ។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងប្រធានចាត់ទុកជាបានការ ។

-ក្នុងករណី quorum មិនគ្រប់ អង្គសន្និបាតលើកទី ២ និងប្រព្រឹត្តទៅក្នុងរយៈពេល ៣ ថ្ងៃ បន្ទាប់ ។ លើកនេះ quorum មិនចាំបាច់ទេ ។ សុពលភាពនៃការសំរេចត្រូវកំណត់ដោយសំឡេងភាគច្រើន ។

**ប្រការ ១១**

មហាសន្និបាតវិសាមញ្ញ អាចកោះអញ្ជើញដោយប្រធានតាមសេចក្តីសំរេចរបស់គណៈកម្មាធិការ ឬ តាមការស្នើសុំដោយសំឡេង ១/៤ នៃចំនួនសមាជិកសកម្ម ។ លក្ខខ័ណ្ឌនៃមហាសន្និបាតវិសាមញ្ញនេះ ត្រូវអនុវត្តន៍ ដូចចែងក្នុងប្រការទី ១០ ដែរ ។

**ប្រការ ១២**

មានតែមហាសន្និបាតទេដែលមានសិទ្ធិកែប្រែលក្ខន្តិកៈសហជីព ។

**ប្រការ ១៣**

-មានតែសមាជិកកិត្តិយស និង សកម្មទេ ដែលមានសិទ្ធិបញ្ចេញសំឡេង ។

-មានតែសមាជិកសកម្មទេ ដែលមានសិទ្ធិឈរឈ្មោះជាប្រធាន ឬ សមាជិក គណៈកម្មាធិការ ។

## ជំពូក IV

## ប្រភពធនធាន

**ប្រការ ១៤**

ប្រភពធនធានសហជីពបានមកពី :

-ប្រាក់បង់ថ្លៃសុំចូលជាសមាជិកសហជីព

-វិភាគទានរបស់សមាជិក

-អំណោយរបស់សប្បុរសជន

-ធនធានដែលបានមកពីប្រភពផ្សេងៗ ដូចជា :

- តំលៃឈ្នួលអាហារដ្ឋាន

-កំរៃផ្ញើកង់ ម៉ូតូ

-តំលៃឈ្នួលកេសដ្ឋ:ដ្ឋាន .....

## ជំពូក V

## ការឧបត្ថម្ភ

<u>ប្រការ ១៥</u>

| | |
|---|---|
| - ឈឺផ្ទាល់ខ្លួន សំរាកពេទ្យ | ឧបត្ថម្ភ : ៥០.០០០៛ |
| - សំរាលកូន | ឧបត្ថម្ភ : ៣០.០០០៛ |
| - ឪពុកម្តាយបង្កើត ស្លាប់ | ឧបត្ថម្ភ : ១០០.០០០៛ |
| - ប្រពន្ធ ឬ ប្តី ស្លាប់ ៉ មានសំបុត្រអាពាហ៍ពិពាហ៍ សលាកប័ត្រផ្ទាល់ខ្លួន ឬ ប្រវត្តិរូប ៉ កូនបង្កើតក្នុងបន្ទុក ៉ ស៊ីប្រាក់ខែ ឬ មានប្រវត្តិរូម ៉ | ឧបត្ថម្ភ : ១០០.០០០៛ |
| - មរណៈភាពផ្ទាល់ខ្លួន ៉ សមាជិក ៉ សមាជិកម្នាក់១ត្រូវចូលរួមមរណៈទុក្ខចំនួន | ឧបត្ថម្ភ : ៥.០០០៛ |
| និង សហជីព | ឧបត្ថម្ភ : ៤០០.០០០៛ |

ក្នុងករណីសមាជិកស្លាប់ គ្មានគ្រួសារ សហជីពទទួលបន្ទុកចំណាយក្នុងការធ្វើបុណ្យសព ។

## ជំពូក VI

## ការរំលាយសហជីព

<u>ប្រការ ១៦</u>.

ការរំលាយសហជីព ចាំបាច់ត្រូវសំរេចដោយសំឡេង ២/៣ យ៉ាងតិចនៃសមាជិកសកម្ម ដែលបានចូលរួមក្នុងមហាសន្និបាត ។ មហាសន្និបាតត្រូវបង្កើតគណៈកម្មការ ជំរះបញ្ជីមួយស្ថិត នៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការសហជីព រហូតដល់ចប់កិច្ចការ ។

************